-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

**សម្រេច**

**មាត្រា ១.**- បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ចំនួន ១៨រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តមង្គលសិរីគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- | ព្រះតេជគុណ **ឡាក់ ឡូ** | ព្រះសមុហ៍អនុគណ | បច្ច័យចំនួន ១០,២០០ដុល្លារ |
| ២- | ព្រះតេជគុណ **ញាណ សាវ៉ុន** | លេខាអនុគណ | បច្ច័យចំនួន ១០,១០០ដុល្លារ |
| ៣- | លោក **ជីង ប៊ុនហេង** | សប្បុរសជន | ថវិកាចំនួន ១២,៣០០ដុល្លារ |
| ៤- | អ្នកស្រី **តាំង សៀមណៃ** | សប្បុរសជន | ថវិកាចំនួន ១១,១០០ដុល្លារ |
| ៥- | លោក **ហ្លួង ហ៊ុយឃុង** | សប្បុរសជន | ថវិកាចំនួន ១០,២៣០ដុល្លារ |
| ៦- | លោក **តាំង សៀមជូ** | សប្បុរសជន | ថវិកាចំនួន ១១,០០០ដុល្លារ |
| ៧- | អ្នកស្រី **តាំង គីមឆាយ** | សប្បុរសជន | ថវិកាចំនួន ១០,០៥០ដុល្លារ |
| ៨- | អ្នកស្រី **អៀ សុខគាង** | សប្បុរសជន | ថវិកាចំនួន ១១,៣០០ដុល្លារ |
| ៩- | លោក **ទ្រី ទ្រង់** | សប្បុរសជន | ថវិកាចំនួន ១០,២៥០ដុល្លារ |
| ១០- | ឧបាសក **សោម គង់** | សប្បុរសជន | ថវិកាចំនួន ១២,៣២០ដុល្លារ |
| ១១- | ឧបាសក **យួន ស៊ីនួន** | សប្បុរសជន | ថវិកាចំនួន ១៣,១៥០ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- | ឧបាសិកា **ស៊ីន តាំងអួន** | សប្បុរសជន | ថវិកាចំនួន ៩,០០០ដុល្លារ |

| | | | |
|---|---|---|---|
| ២- | ឧបាសិកា **ចិន គា** | សប្បុរសជន | ថវិកាចំនួន ៧,១៥០ដុល្លារ |
| ៣- | លោក **ស៊ីង ម្ចុណា** | សប្បុរសជន | ថវិកាចំនួន ៧,២០០ដុល្លារ |
| ៤- | អ្នកស្រី **កែវ ចន្ទសៀក** | សប្បុរសជន | ថវិកាចំនួន ៧,១០០ដុល្លារ |
| ៥- | ឧបាសិក **តាំង ម៉េងគី** | សប្បុរសជន | ថវិកាចំនួន ៧,២៥០ដុល្លារ |
| ៦- | ឧបាសក **ឆូក ហុង** | សប្បុរសជន | ថវិកាចំនួន ៧,២៥០ដុល្លារ |
| ៧- | លោក **ជា កក្កដា** | សប្បុរសជន | ថវិកាចំនួន ៨,១២០ដុល្លារ |

**មាត្រា ២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤៩៦ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**មាត្រា ១** : តែងតាំងកញ្ញា **ស៊ឹម ស្រីលក្ខណ៍** ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧៩៧ អនក្រ.តត

**អនុក្រឹត្យ**
**ស្តីពី**
**ការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- យោងអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងមន្ត្រីរាជការ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម ÷

លោក **ផា អេងវើង** តែងតាំងជាប្រធាននាយកដ្ឋានរបបគយ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៧៩៨ . អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ ចំនួន ០២ រូប ទៅក្នុងឋានន្តរស័ក្តិក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ នៅក្រសួងមុខងារសាធារណៈ ចាប់ពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥ តទៅ ដូចមានរាយនាមខាងក្រោម ៖

១- លោក **ឡូន ស៊ីមួយ** ក្រមការ ថ្នាក់លេខ ៤

២- លោក **ផូ មុនីន** ក្រមការ ថ្នាក់លេខ ៤

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ៧០. ខែ ...... ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៧៩.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងម៉ហាផ្ទៃ

## សម្រេច

**មាត្រា ១** : ផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **ឡាយ សមត្ថា** អត្តលេខ ០៩១០ ពីអនុប្រធាននាយកដ្ឋាននគរបាលអន្តរជាតិ ទៅជាអនុប្រធានសេនាធិការដ្ឋាន ។

**មាត្រា ២** : បទប្បញ្ញត្តទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៩០០ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ អនក្រ.បក ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០០៥ ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្ម និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១:** ប្រគល់ភារកិច្ចជូនលោកអនុសេនីយ៍ឯក **សួន សារ៉ាត** អត្តលេខ ៦២១៣៧ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ឱ្យបំពេញមុខងារជាសមាជិកក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៨៦១ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១ .-** តែងតាំងលោកសាស្ត្រាចារ្យជំនួយ **ម៉ុនចាន់ យុត្តិរុខ** ជាព្រឹទ្ធបុរសមហាវិទ្យាល័យវេជ្ជសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ជំនួសលោកស្រីសាស្ត្រាចារ្យ អ៊ុក សាផៃ ដែលបានចូលនិវត្តន៍ ។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...៦៤...សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបញ្ចប់កិច្ចសន្យារវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុន COSMOS GROUP

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១៖** បញ្ចប់កិច្ចសន្យាចុះថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០០៣ រវាងរាជរដ្ឋាភិបាលកម្ពុជា ហៅថាភាគីអ្នកផ្តល់កិច្ចសន្យា និងក្រុមហ៊ុន COSMOS GROUP តំណាងដោយលោក Eui-Ku Kang ហៅថាភាគីអ្នកផ្តល់សេវាចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ។

**ប្រការ២៖** ប្រគល់ភារកិច្ចឲ្យគណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ចាត់នីតិវិធីបន្តជាមួយក្រុមហ៊ុន COSMOS GROUP តំណាងដោយលោក Eui-Ku Kang ជាភាគីអ្នកផ្តល់សេវាចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ដើម្បីអនុវត្តតាមប្រការ ១ ខាងលើ ។

**ប្រការ៣៖** រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤៖** រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ចំលងជូន:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...៧៥...សសរ

# សេចក្តីសម្រេច

**ស្តីពី**

**ការប្រគល់ភារកិច្ចជូនក្រសួងសាធារណការ និងដឹកជញ្ជូន ឲ្យបន្តការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១៖** ប្រគល់ភារកិច្ចជូនក្រសួងសាធារណការ និងដឹកជញ្ជូន ពិនិត្យលទ្ធភាពបង្កើតគណៈកម្មការជំនាញ ដើម្បីគ្រប់គ្រងបន្តលើនាវាបរទេស ដែលទទួលបានការចុះបញ្ជីដោតទង់ជាតិកម្ពុជា រហូតដល់បញ្ចប់សុពលភាពនៃវិញ្ញាបនបត្រ  ព្រមទាំងទទួលដោះស្រាយនូវរាល់បញ្ហាទាំងឡាយ ដែលអាចកើតមានជាយថាហេតុ បន្ទាប់ពីការបញ្ចប់កិច្ចសន្យា។

**ប្រការ២៖** រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣៖** រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចំលងជូន:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៦៥ សរណន

# សារាចរណែនាំ

## ស្តីពី

## ការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

អនុលោមតាម ព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក ព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដើម្បីបង្កើនប្រសិទ្ធភាពអនុវត្តកាតព្វកិច្ចពាក់ព័ន្ធនឹងការការពារកម្មសិទ្ធិបញ្ញា ការប្រកួតប្រជែងដោយសេរី ការការពារផលប្រយោជន៍អ្នកប្រើប្រាស់ និងសំដៅទប់ស្កាត់អំពើគេចពន្ធ ការលក់តម្លើងថ្លៃ ដែលផ្ទុយនឹងគោលការណ៍ទីផ្សារសេរី និងការនាំចូលនិងលក់ទំនិញក្លែងក្លាយ ព្រមទាំងដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យកសិកម្ម និងវិនិយោគទុននៅកម្ពុជា រាជរដ្ឋាភិបាលសូមធ្វើការណែនាំអំពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ដូចតទៅ៖

១- សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកលើមុខទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ជាធរមាន។

២- ទំនិញនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលដៅមិនធ្វើពាណិជ្ជកម្ម ឬសម្រាប់ប្រើប្រាស់ជាប្រយោជន៍ មនុស្សធម៌ ផ្ទាល់ខ្លួន បេសកកម្មការទូត សហគមន៍ អង្គការជាតិ និងអន្តរជាតិ ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ការផ្គុំតម្លើង និងកែច្នៃបន្ថែម ការពិសោធន៍ និងស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រ ទំនិញគំរូសម្រាប់តាំងបង្ហាញ អភិវឌ្ឍន៍កសិកម្ម កិច្ចសន្យាផលិតកម្មកសិកម្ម គម្រោងវិនិយោគឯកជន វិនិយោគសាធារណៈ ឬទំនិញប្រើរួចគ្រប់ប្រភេទ មិនស្ថិតក្រោមវិសាលភាពអនុវត្តនៃការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខឡើយ។

៣- ចំពោះទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន អាចអនុញ្ញាតឲ្យធ្វើការកត់ត្រាទទួលស្គាល់លិខិតប្រគល់សិទ្ធិនាំចូលជាទំនិញពាក់ម៉ាកផ្តាច់មុខនៅក្រសួងពាណិជ្ជកម្មបាន លុះត្រាតែមានលិខិតអនុញ្ញាតនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាលជាមុនសិន។

៤- អ្នកទិញយកទៅប្រើប្រាស់ ឬដេប៉ូលក់ចែកចាយបន្ត អាចទិញទំនិញពីអ្នកចែកចាយប្រចាំបណ្តាខេត្ត រាជធានី ឬតំបន់ផ្សេងទៀត ក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានការរើសអើង។ ក្នុងករណីដែលក្រសួងមានសមត្ថកិច្ចរកឃើញថា ក្រុមហ៊ុនណាមួយអនុវត្តផ្ទុយនឹងការណែនាំនេះ នឹងត្រូវបានធ្វើមោឃភាពនូវលិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ឬទទួលទោសប្បញ្ញត្តិចែងក្នុងមាត្រាច្បាប់ជាធរមាន។

៥- ក្រសួងពាណិជ្ជកម្ម ត្រូវចេញប្រកាសកំណត់នីតិវិធីលម្អិតស្តីពី ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខឲ្យមានអនុលោមភាពតាមកិច្ចព្រមព្រៀងអន្តរជាតិ បញ្ញត្តិនៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន និងស្របតាមសារាចរណែនាំនេះ សំដៅធានាឲ្យបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ និងបម្រើឲ្យផលប្រយោជន៍របស់អ្នកប្រើប្រាស់ និងសាធារណជនទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦- ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបណ្តាក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវចុះណែនាំដល់ក្រុមហ៊ុន អាជីវករ និងប្រជាជន អំពីខ្លឹមសារសារាចរណែនាំនេះ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយឲ្យបានទូលាយ និងអនុវត្តក្នុងដែនសមត្ថកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាព និងប្រកបទៅដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៧១៩...សហវ.ប្រក

# ប្រកាសរួម
## ស្តីពី
## ការផ្តល់រង្វាន់លើកទឹកចិត្ត
## ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៨/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ ៣១៧ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ .-**

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២ .-**

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នារវាងរដ្ឋបាលកណ្តាល និងមន្ទីររាជធានី ខេត្ត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើក្របខ័ណ្ឌសមត្ថកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈដែលអនុវត្តដោយមន្ទីររាជធានី ខេត្ត។

**ប្រការ ៣ .-**

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួន ពីការ

ផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដូចបានកំណត់ដោយប្រកាសរួមលេខ៩៦១៩ សហវ.ប្រក ចុះថ្ងៃទី..០៩. ខែ.កក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថាថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទាន សម្រាប់ការចំណាយដូចបានកំណត់នៅក្នុងប្រការ ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៤ ..**

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ÷

ក. ចំណូលពីសេវាសាធារណៈ ដែលអនុវត្តតាមតារាងឧបសម្ព័ន្ធទី១ ភ្ជាប់នឹងប្រកាសរួមលេខ៩៦១៩ សហវ.ប្រក ចុះថ្ងៃទី.០៩.. ខែ.កក្កដា. ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ក.១- ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ
- ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ

ក.២- ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ
- ជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ

ខ. ចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ ដែលអនុវត្តតាមតារាងឧបសម្ព័ន្ធទី២ ភ្ជាប់នឹងប្រកាសរួមលេខ ៩៦១៩ សហវ.ប្រក ចុះថ្ងៃទី..០៩. ខែ.កក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ខ.១- ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចំនួន ៤៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលដែលប្រមូលបាន។

ខ.២- ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ចំនួន ៤៩% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃចំណូលដែលប្រមូលបាន។

**ប្រការ ៥ .-**

រដ្ឋបាលកណ្តាលនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ទូទាត់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ទូទាត់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ ( ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

**ប្រការ ៦ .-**

ការទូទាត់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ÷

ក. ផ្នែកចំណូល

ធ្វើសលាកប័ត្រចំណូលថវិកាជាតិនូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន និងសំណើសុំកត់ត្រាចំណូល ÷

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម: ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងស្តីពីការគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។
- ចំពោះមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត: ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងស្តីពីការគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវចេញលិខិតពិនិត្យ បញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

ខ. ផ្នែកចំណាយ

រដ្ឋបាលកណ្តាល និងមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវធ្វើសំណើសុំទូទាត់ចំណាយប្រាក់រង្វាន់លើកទឹកចិត្ត និងធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៧ .-**

ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តដូចខាងក្រោម ÷

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ ៨ .-**

បទប្បញ្ញត្តិទាំងឡាយនៃប្រកាសរួមលេខ ១០០៦ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

<u>កន្លែងទទួល</u> ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត

«ដើម្បីជូនជ្រាប»
- ដូចប្រការ ៩ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ...៧៤១៨ សហវ.ប្រក...ចុះថ្ងៃទី...០៩... ខែ...កក្កដា... ឆ្នាំ២០១៥

ស្តីពីការផ្តល់ទឹកប្រាក់លើកទឹកចិត្តជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក ឧស | ក សហវ |
| I. អគ្គនាយកដ្ឋានឧស្សាហកម្ម | | | | |
| ក. នាយកដ្ឋានកិច្ចការឧស្សាហកម្ម | | | | |
| ១ | ប្រកាសបង្កើតរោងចក្រ (ដើមទុនលើសពី ៥០០ ០០០ដុល្លារឡើង) | ៥០% | ៤៩% | ១% |
| ២ | ប្រកាសបង្កើតសាខារោងចក្រ (ដើមទុនលើសពី ៥០០ ០០០ដុល្លារឡើង) | ៥០% | ៤៩% | ១% |
| ៣ | ការផ្តល់វិញ្ញាបនបត្រថ្មី និងបន្ត (ដើមទុនលើសពី ៥០០ ០០០ដុល្លារឡើង) | ៥០% | ៤៩% | ១% |
| | + លិខិតបញ្ជាក់លើ ÷ | | | |
| ៤ | - ពង្រីកផលិតកម្ម | ៥០% | ៤៩% | ១% |
| ៥ | - ប្តូរទីតាំងរោងចក្រ | ៥០% | ៤៩% | ១% |
| ៦ | - ប្តូរម្ចាស់ភាគហ៊ុន | ៥០% | ៤៩% | ១% |
| ៧ | - ប្តូរឈ្មោះរោងចក្រ | ៥០% | ៤៩% | ១% |
| ៨ | ចុះបញ្ជីរោងចក្រ (ដើមទុនលើសពី ៥០០ ០០០ដុល្លារឡើង) | ៥០% | ៤៩% | ១% |
| ៩ | លិខិតបញ្ជាក់ទុតិយតា | ៥០% | ៤៩% | ១% |
| ១០ | លិខិតបញ្ជាក់ផ្សេងទៀតចាំបាច់មានដូចជា ការទិញរោងចក្រ ភាពជាម្ចាស់គម្រោង ការបញ្ជាក់ទំនិញប្រភពដើម និងបរិមាណប្រើប្រាស់ និងការបញ្ជាក់ធាតុចូលផលិតកម្ម | ៥០% | ៤៩% | ១% |
| ខ. នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | | | | |
| | + លិខិតបញ្ជាក់លក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្មលើឡចំហាយ ម៉ាស៊ីនភ្លើង គ្រឿងចក្រ និងខ្សែសង្វាក់ផលិតកម្ម ÷ | | | |
| ១១ | - សិប្បកម្ម | ៥០% | ៤៩% | ១% |
| ១២ | - សហគ្រាសធុនតូច និងមធ្យម | ៥០% | ៤៩% | ១% |
| ១៣ | - រោងចក្រ | ៥០% | ៤៩% | ១% |
| | + លិខិតបញ្ជាក់លើបរិមាណប្រើប្រាស់វត្ថុធាតុដើម ឧបករណ៍បរិក្ខារ និងមុខសញ្ញាប្រើប្រាស់ ÷ | | | |
| ១៤ | - សិប្បកម្ម | ៥០% | ៤៩% | ១% |
| ១៥ | - សហគ្រាសធុនតូច និងមធ្យម | ៥០% | ៤៩% | ១% |
| ១៦ | - រោងចក្រ | ៥០% | ៤៩% | ១% |
| ១៧ | លិខិតបញ្ជាក់លើការរៀបចំប្រព័ន្ធប្រព្រឹត្តកម្ម ការទុកដាក់សំណល់រាវ សំណល់រឹង ឧស្ម័ន និងប្រព័ន្ធលំហូរខ្យល់ ដែលខុសពីលក្ខណៈបច្ចេកទេស ដែលកំណត់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ៥០% | ៤៩% | ១% |
| គ. នាយកដ្ឋានវាយតម្លៃទទួលស្គាល់ | | | | |
| ១៨ | ចុះបញ្ជីអង្គភាពចេញវិញ្ញាបនបត្រវាយតម្លៃភាពអនុលោម | ៥០% | ៤៩% | ១% |
| | + វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់មន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត ÷ | | | |
| ១៩ | - ផ្តល់វិញ្ញាបនបត្រវាយតម្លៃ ទទួលស្គាល់លើកដំបូង | ៥០% | ៤៩% | ១% |
| ២០ | - ផ្តល់វិញ្ញាបនបត្រវាយតម្លៃ ទទួលស្គាល់បន្តសុពលភាព | ៥០% | ៤៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក ឧស | ក សហវ |
| | + វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ដល់អង្គភាពចេញវិញ្ញាបនបត្រវាយតម្លៃភាពអនុលោមស្តង់ដារ÷ | | | |
| ២១ | - ផ្តល់វិញ្ញាបនបត្រវាយតម្លៃ ទទួលស្គាល់លើកដំបូង | ៥០% | ៤៩% | ១% |
| ២២ | - ផ្តល់វិញ្ញាបនបត្រវាយតម្លៃ ទទួលស្គាល់បន្តសុពលភាព | ៥០% | ៤៩% | ១% |
| | + វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ដល់អង្គភាពអធិកាកិច្ច÷ | | | |
| ២៣ | - ផ្តល់វិញ្ញាបនបត្រវាយតម្លៃ ទទួលស្គាល់លើកដំបូង | ៥០% | ៤៩% | ១% |
| ២៤ | - ផ្តល់វិញ្ញាបនបត្រវាយតម្លៃ ទទួលស្គាល់បន្តសុពលភាព | ៥០% | ៤៩% | ១% |
| ឃ. នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម | | | | |
| | ឃ.១- ការផ្តល់ប្រកាសនីយបត្រតក្កម្ម | | | |
| | + ការស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម÷ | | | |
| ២៥ | - សេចក្តីអះអាង ១០ដំបូង | ៥០% | ៤៩% | ១% |
| ២៦ | - សេចក្តីអះអាងលើសពី ១០ដំបូង | ៥០% | ៤៩% | ១% |
| ២៧ | ការបញ្ជាក់ និងផ្តល់វិញ្ញាបនបត្រលើការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ | ៥០% | ៤៩% | ១% |
| ២៨ | ការផ្តល់អាជ្ញាប័ណ្ណបញ្ជា | ៥០% | ៤៩% | ១% |
| ២៩ | ការប្តឹងលើការរំលោភបំពាន និង ដោះស្រាយវិវាទ | ៥០% | ៤៩% | ១% |
| ៣០ | ការបញ្ជាក់លើឯកសារថតចម្លង | ៥០% | ៤៩% | ១% |
| ៣១ | ការផ្តល់ប្រកាសនីយបត្រតក្កកម្ម | ៥០% | ៤៩% | ១% |
| | + ការបង់កម្រៃប្រចាំឆ្នាំ ដើម្បីរក្សាសុពលភាពសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងប្រកាសនីយបត្រតក្កកម្ម (ចាប់ពីរយៈពេល១ឆ្នាំ ក្រោយកាលបរិច្ឆេទស្នើសុំ)÷ | | | |
| ៣២ | - ឆ្នាំទី២ | ៥០% | ៤៩% | ១% |
| ៣៣ | - ឆ្នាំទី៣ | ៥០% | ៤៩% | ១% |
| ៣៤ | - ឆ្នាំទី៤ | ៥០% | ៤៩% | ១% |
| ៣៥ | - ឆ្នាំទី៥ | ៥០% | ៤៩% | ១% |
| ៣៦ | - ឆ្នាំទី៦ | ៥០% | ៤៩% | ១% |
| ៣៧ | - ឆ្នាំទី៧ | ៥០% | ៤៩% | ១% |
| ៣៨ | - ឆ្នាំទី៨ | ៥០% | ៤៩% | ១% |
| ៣៩ | - ឆ្នាំទី៩ | ៥០% | ៤៩% | ១% |
| ៤០ | - ឆ្នាំទី១០ | ៥០% | ៤៩% | ១% |
| ៤១ | - ឆ្នាំទី១១ | ៥០% | ៤៩% | ១% |
| ៤២ | - ឆ្នាំទី១២ | ៥០% | ៤៩% | ១% |
| ៤៣ | - ឆ្នាំទី១៣ | ៥០% | ៤៩% | ១% |
| ៤៤ | - ឆ្នាំទី១៤ | ៥០% | ៤៩% | ១% |
| ៤៥ | - ឆ្នាំទី១៥ | ៥០% | ៤៩% | ១% |
| ៤៦ | - ឆ្នាំទី១៦ | ៥០% | ៤៩% | ១% |
| ៤៧ | - ឆ្នាំទី១៧ | ៥០% | ៤៩% | ១% |
| ៤៨ | - ឆ្នាំទី១៨ | ៥០% | ៤៩% | ១% |
| ៤៩ | - ឆ្នាំទី១៩ | ៥០% | ៤៩% | ១% |
| ៥០ | - ឆ្នាំទី២០ | ៥០% | ៤៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក ឧស | ក សហវ |
| ៥១ | ការពិន័យលើការយឺតយ៉ាវចំពោះការបង់កម្រៃសេវាប្រចាំឆ្នាំ រយៈពេល ៦ខែ (ពិន័យ២% ក្នុង១ខែ នៃឆ្នាំកាតព្វកិច្ចត្រូវបង់ រួមទាំងការប្រាក់ដែលត្រូវគិតតាមរូបមន្តសមាស) | ៥០% | ៤៩% | ១% |
| | ឃ.២- ការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ | | | |
| | + ការស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ | | | |
| ៥២ | - សេចក្តីអះអាង ១០ដំបូង | ៥០% | ៤៩% | ១% |
| ៥៣ | - សេចក្តីអះអាងលើសពី ១០ដំបូង | ៥០% | ៤៩% | ១% |
| ៥៤ | ការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ | ៥០% | ៤៩% | ១% |
| ៥៥ | ការបញ្ជាក់ និងផ្តល់វិញ្ញាបនបត្រ លើការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ | ៥០% | ៤៩% | ១% |
| ៥៦ | ការស្នើសុំអាជ្ញាប័ណ្ណបញ្ជា | ៥០% | ៤៩% | ១% |
| ៥៧ | ការប្តឹងលើការរំលោភបំពាន និងដោះស្រាយវិវាទ | ៥០% | ៤៩% | ១% |
| ៥៨ | ការបញ្ជាក់លើឯកសារថតចម្លង | ៥០% | ៤៩% | ១% |
| | + ការបង់កម្រៃប្រចាំឆ្នាំ ដើម្បីរក្សាសុពលភាពសំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ (ចាប់ពីរយៈពេល១ឆ្នាំក្រោយកាលបរិច្ឆេទស្នើសុំចុះបញ្ជី) ÷ | | | |
| ៥៩ | - ឆ្នាំទី២ | ៥០% | ៤៩% | ១% |
| ៦០ | - ឆ្នាំទី៣ | ៥០% | ៤៩% | ១% |
| ៦១ | - ឆ្នាំទី៤ | ៥០% | ៤៩% | ១% |
| ៦២ | - ឆ្នាំទី៥ | ៥០% | ៤៩% | ១% |
| ៦៣ | - ឆ្នាំទី៦ | ៥០% | ៤៩% | ១% |
| ៦៤ | - ឆ្នាំទី៧ | ៥០% | ៤៩% | ១% |
| ៦៥ | ការពិន័យលើការយឺតយ៉ាវចំពោះការបង់កម្រៃសេវាប្រចាំឆ្នាំ រយៈពេល ៦ខែ (ពិន័យ ២% ក្នុង១ខែ នៃឆ្នាំកាតព្វកិច្ចត្រូវបង់ រួមទាំងការប្រាក់ដែលត្រូវគិតតាមរូបមន្តសមាស) | ៥០% | ៤៩% | ១% |
| | ឃ.៣- ការចុះបញ្ជីបតំនូសបង្ហាញនៃសៀគ្វីបង្រួម | | | |
| ៦៦ | ការស្នើសុំចុះបញ្ជីតំនូសបង្ហាញនៃសៀគ្វីបង្រួម | ៥០% | ៤៩% | ១% |
| ៦៧ | ការផ្តល់វិញ្ញាបនបត្រការចុះបញ្ជីតំនូសបង្ហាញនៃសៀគ្វីបង្រួម | ៥០% | ៤៩% | ១% |
| ៦៨ | ការបញ្ជាក់ និងផ្តល់វិញ្ញាបនបត្រ លើការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ | ៥០% | ៤៩% | ១% |
| ៦៩ | ការប្តឹងលើការរំលោភបំពាន និងដោះស្រាយវិវាទ | ៥០% | ៤៩% | ១% |
| ៧០ | ការបញ្ជាក់លើឯកសារថតចម្លង | ៥០% | ៤៩% | ១% |
| | ឃ.៤- ការចុះបញ្ជីគំនូរឧស្សាហកម្ម | | | |
| ៧១ | ការស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម | ៥០% | ៤៩% | ១% |
| ៧២ | ការផ្តល់វិញ្ញាបនបត្រចុះបញ្ជីគំនូរឧស្សាហកម្ម រយៈពេល៥ឆ្នាំ ដំបូង | ៥០% | ៤៩% | ១% |
| ៧៣ | ការចុះបញ្ជីសាឡើងវិញ រយៈពេល៥ឆ្នាំ លើកទី១ (ចាប់ពី ឆ្នាំទី៦ ដល់ ឆ្នាំទី១០) | ៥០% | ៤៩% | ១% |
| ៧៤ | ការចុះបញ្ជីសាឡើងវិញ រយៈពេល៥ឆ្នាំ លើកទី២ (ចាប់ពី ឆ្នាំទី១០ ដល់ឆ្នាំទី១៥) | ៥០% | ៤៩% | ១% |
| ៧៥ | ការបញ្ជាក់លើឯកសារថតចម្លង | ៥០% | ៤៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក ឧស | ក សហវ |
| ៧៦ | ការបញ្ជាក់លើការកត់ត្រាកិច្ចសន្យាអាជ្ញាប័ណ្ណ ឬប្តូរម្ចាស់កម្មសិទ្ធិ | ៥០% | ៤៩% | ១% |
| ៧៧ | ការប្តឹងលើការរំលោភបំពាន និងដោះស្រាយវិវាទ | ៥០% | ៤៩% | ១% |
| ៧៨ | ពិន័យលើការយឺតយ៉ាវចំពោះការបង់កម្រៃនៃការចុះបញ្ជីឡើងវិញ រយៈពេល ៦ខែ (ពិន័យ ២%ក្នុង១ខែនៃឆ្នាំកាតព្វកិច្ចត្រូវបង់ រួមទាំងការប្រាក់ដែលត្រូវគិតតាមរូបមន្តសមាស) | ៥០% | ៤៩% | ១% |
| | ឃ.៥- ការបោះពុម្ពផ្សាយ | | | |
| ៧៩ | ការបោះពុម្ពផ្សាយចំពោះការផ្តល់ប្រកាសនីយបត្រតក្កកម្មសម្រាប់ផ្សព្វផ្សាយជូនសាធារណជន | ៥០% | ៤៩% | ១% |
| ៨០ | ការបោះពុម្ពផ្សាយចំពោះការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍សម្រាប់ផ្សព្វផ្សាយជូនសាធារណជន | ៥០% | ៤៩% | ១% |
| ៨១ | ការបោះពុម្ពផ្សាយចំពោះការផ្តល់វិញ្ញាបនបត្រគំនូសបង្ហាញសៀគ្វីបង្រួម ម៉ូដែលមានអត្ថប្រយោជន៍ សម្រាប់ផ្សព្វផ្សាយជូនសាធារណជន | ៥០% | ៤៩% | ១% |
| ៨២ | ការបោះពុម្ពផ្សាយការចុះបញ្ជីគំនូរឧស្សាហកម្មសម្រាប់ផ្សព្វផ្សាយជូនសាធារណជន | ៥០% | ៤៩% | ១% |
| ៨៣ | ការបោះពុម្ពផ្សាយការចុះបញ្ជីគំនូរឧស្សាហកម្មសារឡើង សម្រាប់ផ្សព្វផ្សាយជូនសាធារណជន | ៥០% | ៤៩% | ១% |
| ង. មជ្ឈមណ្ឌលផលិតភាពជាតិ | | | | |
| ៨៤ | សេវាបណ្តុះបណ្តាលអំពីវិធីសាស្ត្រផលិតភាព និងស៥ (១ថ្ងៃ/នាក់) តាមការស្ម័គ្រចិត្ត | ៥០% | ៤៩% | ១% |
| ៨៥ | ចេញ និងបន្តវិញ្ញាបនបត្រដាក់និមិត្តសញ្ញា ស៥ នៅលើផលិតផល (តំបន់១÷ រាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ) | ៥០% | ៤៩% | ១% |
| ៨៦ | ចេញ និងបន្តវិញ្ញាបនបត្រដាក់និមិត្តសញ្ញា ស៥ នៅលើផលិតផល (តំបន់២÷ ខេត្តតាកែវ ព្រៃវែង កំពង់ឆ្នាំង ស្វាយរៀង កំពង់ចាម ត្បូងឃ្មុំ កំពត កំពង់ធំ កែប ពោធិសាត់ និងខេត្តព្រះសីហនុ) | ៥០% | ៤៩% | ១% |
| ៨៧ | ចេញ និងបន្តវិញ្ញាបនបត្រដាក់និមិត្តសញ្ញា ស៥ នៅលើផលិតផល (តំបន់៣ ÷ ខេត្តកោះកុង បាត់ដំបង ព្រះវិហារ សៀមរាប ក្រចេះ បន្ទាយមានជ័យ ប៉ៃលិន ស្ទឹងត្រែង ឧត្តរមានជ័យ មណ្ឌលគិរី និងខេត្តរតនគិរី) | ៥០% | ៤៩% | ១% |
| ច. នាយកដ្ឋានទឹកស្អាត | | | | |
| | ច.១- ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ÷ | | | |
| ៨៨ | ចំនួនតំណតិចជាង ឬស្មើ ៥០០តំណ ÷ | ៥០% | ៤៩% | ១% |
| ៨៩ | ចំនួនតំណចាប់ពី ៥០១តំណ ដល់ ២ ០០០តំណ ÷ | ៥០% | ៤៩% | ១% |
| ៩០ | ចំនួនតំណចាប់ពី ២ ០០១តំណ ដល់ ៥ ០០០តំណ ÷ | ៥០% | ៤៩% | ១% |
| ៩១ | ចំនួនតំណចាប់ពី ៥ ០០១តំណ ដល់ ១០ ០០០តំណ ÷ | ៥០% | ៤៩% | ១% |
| ៩២ | ចំនួនតំណចាប់ពី ១០ ០០១ តំណឡើងទៅ ÷ | ៥០% | ៤៩% | ១% |
| | ច.២- ការផ្តល់វិញ្ញាបនបត្រប្រតិបត្តិការ ÷ | | | |
| ៩៣ | - ការបង់ថ្លៃសេវាប្រចាំឆ្នាំ ចំពោះតំណតិចជាង ឬស្មើ ៥០០តំណ | ៥០% | ៤៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក ខុស | ក សហវ |
| ៩៤ | - ការបង់ថ្លៃសេវាប្រចាំឆ្នាំ ចំពោះតំណចាប់ពី ៥០១តំណ ដល់ ២ ០០០តំណ | ៥០% | ៤៩% | ១% |
| ៩៥ | ការបង់ថ្លៃសេវាប្រចាំឆ្នាំ ចំពោះតំណចាប់ពី ២ ០០១តំណ ដល់ ៥ ០០០តំណ | ៥០% | ៤៩% | ១% |
| ៩៦ | - ការបង់ថ្លៃសេវាប្រចាំឆ្នាំ ចំពោះតំណចាប់ពី ៥ ០០១តំណ ដល់ ១០ ០០០តំណ | ៥០% | ៤៩% | ១% |
| ៩៧ | - ការបង់ថ្លៃសេវាប្រចាំឆ្នាំ ចំពោះតំណចាប់ពី ១០ ០០១តំណឡើង | ៥០% | ៤៩% | ១% |
| II. អគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម | | | | |
| ១ | ការចុះបញ្ជីសិប្បកម្ម (ដើមទុនតិចជាង ឬស្មើ ៥០ ០០០ដុល្លារ) | ៥០% | ៤៩% | ១% |
| | + ប្រកាសបង្កើតរោងចក្រធុនតូច មធ្យម និងសិប្បកម្ម÷ | | | |
| ២ | -សិប្បកម្ម (ដើមទុនតិចជាង ឬស្មើ ៥០ ០០០ដុល្លារ) | ៥០% | ៤៩% | ១% |
| ៣ | - រោងចក្រធុនតូច (ដើមទុនលើសពី ៥០ ០០០ដុល្លារ ដល់ ២៥០ ០០០ដុល្លារ) | ៥០% | ៤៩% | ១% |
| ៤ | - រោងចក្រធុនមធ្យម (ដើមទុនលើសពី ២៥០ ០០០ដុល្លារ ដល់ ៥០០ ០០០ដុល្លារ) | ៥០% | ៤៩% | ១% |
| | + វិញ្ញាបនបត្រដំណើរការរោងចក្រធុនតូច មធ្យម និងសិប្បកម្ម (ថ្មី ឬបន្ត)÷ | | | |
| ៥ | -សិប្បកម្ម (ដើមទុនតិចជាង ឬស្មើ ៥០ ០០០ដុល្លារ) | ៥០% | ៤៩% | ១% |
| ៦ | - រោងចក្រធុនតូច (ដើមទុនលើសពី ៥០ ០០០ដុល្លារ ដល់ ២៥០ ០០០ដុល្លារ) | ៥០% | ៤៩% | ១% |
| ៧ | - រោងចក្រធុនមធ្យម (ដើមទុនលើសពី ២៥០ ០០០ដុល្លារ ដល់ ៥០០ ០០០ដុល្លារ) | ៥០% | ៤៩% | ១% |
| | + លិខិតអនុញ្ញាតពង្រីកផលិតកម្ម ឬប្តូរទីតាំង ឬប្តូរម្ចាស់ ឬប្តូរឈ្មោះ ឬទុតិយតា÷ | | | |
| ៨ | -សិប្បកម្ម (ដើមទុនតិចជាង ឬស្មើ ៥០ ០០០ដុល្លារ) | ៥០% | ៤៩% | ១% |
| ៩ | - រោងចក្រធុនតូច (ដើមទុនលើសពី ៥០ ០០០ដុល្លារ ដល់ ២៥០ ០០០ដុល្លារ) | ៥០% | ៤៩% | ១% |
| ១០ | - រោងចក្រធុនមធ្យម (ដើមទុនលើសពី ២៥០ ០០០ដុល្លារ ដល់ ៥០០ ០០០ដុល្លារ) | ៥០% | ៤៩% | ១% |
| III. វិទ្យាស្ថានស្តង់ដារកម្ពុជា | | | | |
| ក. ការផ្តល់អាជ្ញាប័ណ្ណប្រើសញ្ញាអនុលោមស្តង់ដារផលិតផល (តាមការស្នើសុំ)÷ | | | | |
| ១ | - ចុះត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធផលិតកម្មអនុលោមស្តង់ដារផលិតផល (សម្រាប់១នាក់/១ថ្ងៃ) | ២០% | ៧៩% | ១% |
| ២ | - វិញ្ញាបនបត្របញ្ជាក់ភាពអនុលោមផលិតផល | ២០% | ៧៩% | ១% |
| ៣ | - ថ្លៃអាជ្ញាប័ណ្ណ | ៥០% | ៤៩% | ១% |
| ខ. ការផ្តល់អាជ្ញាប័ណ្ណចុះបញ្ជីផលិតផលប្រើសញ្ញាស្តង់ដារកម្ពុជា (ចបផ, សុវត្ថិភាព) | | | | |
| ៤ | - សម្រាប់ផលិតផលអគ្គិសនី និងអេឡិចត្រូនិក | ៥០% | ៤៩% | ១% |
| ៥ | - សម្រាប់ផលិតផលម្ហូបអាហារ | ៥០% | ៤៩% | ១% |
| ៦ | - សម្រាប់ផលិតផលកៅស៊ូ | ៥០% | ៤៩% | ១% |
| ៧ | - សម្រាប់ផលិតផលឈើ | ៥០% | ៤៩% | ១% |
| ៨ | - សម្រាប់ផលិតផលយានយន្ត | ៥០% | ៤៩% | ១% |
| ៩ | - សម្រាប់ផលិតផលគីមី | ៥០% | ៤៩% | ១% |
| ១០ | - សម្រាប់ផលិតផលសម្ភារសំណង់ | ៥០% | ៤៩% | ១% |
| ១១ | - សម្រាប់ផលិតផលផ្សេងៗ | ៥០% | ៤៩% | ១% |
| ១២ | ការចុះបញ្ជិកា និងចេញទិដ្ឋាការ សម្រាប់ការទទួលបានវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ | ៥០% | ៤៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក ទុស | ក សហវ |
| គ. វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រង (តាមការស្នើសុំ) | | | | |
| | គ.១- វិញ្ញាបនបត្រ GMP/GHP | | | |
| ១៣ | - ការចុះវាយតម្លៃ និងផ្ទៀងផ្ទាត់ការអនុវត្តប្រព័ន្ធគ្រប់គ្រង សម្រាប់ ១នាក់/១ថ្ងៃ (តាមការស្នើសុំ) | ២០% | ៧៩% | ១% |
| ១៤ | - ការចេញវិញ្ញាបនបត្រការអនុវត្តផលិតកម្មល្អ (GMP), អនាម័យល្អ (GHP) | ២០% | ៧៩% | ១% |
| | គ.២- វិញ្ញាបនបត្រ HACCP/ISO 9001 | | | |
| ១៥ | - ការចុះវាយតម្លៃ និងផ្ទៀងផ្ទាត់ការអនុវត្តប្រព័ន្ធគ្រប់គ្រង សម្រាប់ ១នាក់/១ថ្ងៃ (តាមការស្នើសុំ) | ២០% | ៧៩% | ១% |
| ១៦ | - ការចេញវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធនៃការអនុវត្តប្រព័ន្ធសុវត្ថិភាពម្ហូបអាហារ (HACCP) ឬ ប្រព័ន្ធគ្រប់គ្រងគុណភាព(ISO 9001) | ២០% | ៧៩% | ១% |
| | គ.៣- វិញ្ញាបនបត្រ ISO 14001/ISO 22000 | | | |
| ១៧ | - ការចុះវាយតម្លៃ និងផ្ទៀងផ្ទាត់ការអនុវត្តប្រព័ន្ធគ្រប់គ្រង សម្រាប់ ១នាក់/១ថ្ងៃ (តាមការស្នើសុំ) | ២០% | ៧៩% | ១% |
| ១៨ | - ការចេញវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថាន (ISO 14001) ឬប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ (ISO 22000) | ២០% | ៧៩% | ១% |
| ឃ. ការពិគ្រោះផ្តល់យោបល់សម្រាប់ផលិតផល និងការអនុវត្តប្រព័ន្ធ សម្រាប់ ១នាក់/១ថ្ងៃ (តាមការស្នើសុំ) | | | | |
| ១៩ | - ការផ្តល់ការពិគ្រោះយោបល់សម្រាប់ផលិតផល | ២០% | ៧៩% | ១% |
| ២០ | - ការផ្តល់ការពិគ្រោះយោបល់សម្រាប់ការអនុវត្តប្រព័ន្ធ GMP ឬ GHP | ២០% | ៧៩% | ១% |
| ២១ | - ការពិគ្រោះយោបល់សម្រាប់ការអនុវត្តប្រព័ន្ធ HACCP, ISO 9001 ឬ 14001 | ២០% | ៧៩% | ១% |
| ២២ | - ការផ្តល់ការពិគ្រោះយោបល់សម្រាប់ការអនុវត្តប្រព័ន្ធ ISO 22000 | ២០% | ៧៩% | ១% |
| ង. លិខិតបញ្ជាក់មុខសញ្ញា និង/ឬស្តង់ដារប្រើប្រាស់សារធាតុគីមី | | | | |
| ២៣ | - តម្លៃនាំចូល ឬនាំចេញតិចជាង ឬស្មើ ២ ០០០ ០០០រៀល | ៥០% | ៤៩% | ១% |
| ២៤ | - តម្លៃនាំចូល ឬនាំចេញលើសពី ២ ០០០ ០០០រៀល ដល់ ៥ ០០០ ០០០រៀល | ៥០% | ៤៩% | ១% |
| ២៥ | - តម្លៃនាំចូល ឬនាំចេញលើសពី ៥ ០០០ ០០០រៀល ដល់ ១០ ០០០ ០០០រៀល | ៥០% | ៤៩% | ១% |
| ២៦ | - តម្លៃនាំចូល ឬនាំចេញលើសពី ១០ ០០០ ០០០រៀល ដល់ ២០ ០០០ ០០០រៀល | ៥០% | ៤៩% | ១% |
| ២៧ | - តម្លៃនាំចូល ឬនាំចេញលើសពី ២០ ០០០ ០០០រៀល ដល់ ៥០ ០០០ ០០០រៀល | ៥០% | ៤៩% | ១% |
| ២៨ | - តម្លៃនាំចូល ឬនាំចេញលើសពី ៥០ ០០០ ០០០រៀល ដល់ ១០០ ០០០ ០០០រៀល | ៥០% | ៤៩% | ១% |
| ២៩ | - តម្លៃនាំចូល ឬនាំចេញលើសពី ១០០ ០០០ ០០០រៀល ដល់ ៥០០ ០០០ ០០០រៀល | ៥០% | ៤៩% | ១% |
| ៣០ | - តម្លៃនាំចូល ឬនាំចេញលើសពី ៥០០ ០០០ ០០០រៀលឡើង | ៥០% | ៤៩% | ១% |
| ច. មជ្ឈមណ្ឌលមន្ទីរពិសោធន៍នុស្សាហកម្មកម្ពុជា (ប៉ារ៉ាម៉ែត្រធ្វើតេស្តវិភាគ) | | | | |
| | ច.១- ការធ្វើតេស្តវិភាគមីក្រូជីវសាស្ត្រ (Microbiological Test) | | | |
| | + ការធ្វើតេស្តវិភាគមីក្រូជីវសាស្ត្រសម្រាប់ទឹក និងទឹកកក (Microbiological Test for Water and Ice) ÷ | | | |
| ៣១ | បាក់តេរីសរុប (Total Bacteria, CFU) 22©C, 68h | ២០% | ៧៩% | ១% |
| ៣២ | បាក់តេរីសរុប (Total Bacteria, CFU) 36©C, 44h | ២០% | ៧៩% | ១% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក ឱុស | ក សហវ |
| ៣៣ | កូលីហ្វមសរុប (Total Coliform, MPN or CFU) | ២០% | ៧៩% | ១% |
| ៣៤ | ទែម៉ូតូឡេរ៉ង់កូលីហ្វម (Thermotolerant Coliform, MPN) | ២០% | ៧៩% | ១% |
| ៣៥ | អ៊ីកូឡាយ (presumptive *E. coli*, MPN or CFU) | ២០% | ៧៩% | ១% |
| ៣៦ | ក្រុម D ស្រ្តេបតូកូគីស (Group D Streptococcus, MPN) | ២០% | ៧៩% | ១% |
| ៣៧ | អង់តេរ៉ូកុកស៊ី (Intestinal Enterococci, CFU) | ២០% | ៧៩% | ១% |
| ៣៨ | ស៊ុលហ្វិតរ៉េឌុស៊ីងអាណាអ៊ែរ៉ូប (Sulphite-Reducing Anaerobe) | ២០% | ៧៩% | ១% |
| ៣៩ | ភ្សីដូម៉ូណាស់អារូហ្សីណូហ្សា (*Pseudomonas aoruginosa*) | ២០% | ៧៩% | ១% |
| | + ការធ្វើតេស្តវិភាគមីក្រូជីវសាស្រ្តសម្រាប់ម្ហូបអាហារ និងភេសជ្ជៈ (Microbiological Test for Food and Beverage) ÷ | | | |
| ៤០ | បាក់តេរីសរុប (Total Bacteria, CFU) 30©C, 72h | ២០% | ៧៩% | ១% |
